The Royal Women's Hospital Women's Health Information

# ការព្យាបាល endometriosis (ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង) ដោយប្រើវិធីវះឆ្លុះមើលក្នុងសំបុកពោះ

*ខែមីនា ឆ្នាំ 2004*

## ហេតុអ្វីបានជាប្រើវិធីវះឆ្លុះមើលក្នុងសំបុកពោះ (Laparoscopy)?

វេជ្ជបណ្ឌិតអ្នកសង្ស័យថា អ្នកអាចកើតមានជំងឺ endometriosis (ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង) ហើយបានផ្តល់ឲ្យអ្នកនូវជំរើសក្នុងការប្រើវិធីវះឆ្លុះមើលក្នុងសំបុកពោះ។

បើអ្នកចង់ដឹងថែមទៀតអំពី endometriosis និងជំរើសព្យាបាលដែលអ្នកមាន សូមអានប័ណ្ណពត៌មាន *Endometriosis (ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង) – ពត៌មានសំរាប់ស្ត្រី* និង *ការព្យាបាល Endometriosis (ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង)*។

គុណប្រយោជន៏នៃវិធីវះឆ្លុះមើលក្នុងសំបុកពោះ គឺថា គេអាចបញ្ជាក់អំពីរោគវិនិច្ឆ័យរបស់អ្នក ហើយគេអាចធ្វើការព្យាបាលនៅគ្រាជាមួយគ្នាតែម្តង។ គុណប្រយោជន៏មួយទៀតនៃវិធីវះឆ្លុះមើលក្នុងសំបុកពោះ គឺថា គេអាចប្រើវិធីនេះដើម្បីរកមើលដឹងទីកន្លែងកើតមាន endometriosis និងទំហំរបស់វា ព្រមទាំងការធ្វើឲ្យប្រាកដថា ពុំមានបញ្ហាជំងឺឯទៀតដែលកំពុងបណ្តាលឲ្យមានរោគសញ្ញារបស់អ្នកឡើយ។

## តើវិធីវះឆ្លុះមើលក្នុងសំបុកពោះ គឺជាអ្វីទៅ?

វិធីនេះជាប្រតិបត្តិការមួយដែលគេស៊កបញ្ចូលកែវឃើតតូចឆ្មារមួយ តាមរយៈការវះតូចមួយនៅនឹងផ្ចិតអ្នក ដើម្បីមើលក្រហូងពោះ និង ម្តុំសាច់ដុំឆ្អឹងត្រគាក។ ការវះតូចៗថែមទៀត គឺជាការចាំបាច់ដើម្បីឲ្យគេអាចប្រើសម្ភារៈផ្សេងទៀតសំរាប់ធ្វើទំរង់ការនេះ។ ការវះទាំងនេះត្រូវបានបិទភ្ជិតដោយប្រើចំណុចដេរតែមួយគត់ ឬបង់បិទមុខ។

## តើវិធីនេះត្រូវបានប្រើយ៉ាងណាដែរ?

បើគេអាចមើលឃើញ endometriosis ក្នុងអម្លុងវិធីវះឆ្លុះមើលក្នុងសំបុកពោះ ជាធម្មតាគេនឹងយកសំណាកមួយទៅវិភាគមើល។ អំពើនេះនឹងបញ្ជាក់នូវការពិតនៃរោគវិនិច្ឆ័យ។

ការព្យាបាលនឹងអាស្រ័យទៅលើទីកន្លែងដែលរកឃើញវា និងទំហំរបស់វា។

គេអាចយកចេញនូវស្នាមតូចៗនៃ endometriosis នៅម្តុំសាច់ដុំឆ្អឹងត្រគាក តាមរយៈការវះកាត់ ឬ ដោយដុត (ប្រើកំដៅអគ្គិសនី ឬ ឡាស៊ែរ)។ ជាធម្មតា endometriosis នៅនឹងអូវ៉ែរ តម្រូវឲ្យកាត់យកចេញពងដុះចេញដែលគេហៅថា ពងដុះនៃ endometriosis (endometrioma)។

ជួនកាលទៅ endometriosis មានផលប៉ះពាល់ដល់សរីរាង្គផ្សេងទៀត ដូចជាពោះវៀន ឬ បំពង់នោម (បំពង់ចេញពីតម្រងនោមទៅកាន់ប្លោកនោម)ជាដើម។ បើសិនជាយ៉ាងនេះមែន អ្នកអាចត្រូវការការវះកាត់បន្ថែមនៅថ្ងៃក្រោយទៀត។ ការវះកាត់ថែមទៀត ទំនងជាចូលរួមធ្វើដោយគ្រូពេទ្យវះកាត់ឯកទេសផ្សេងទៀត។

## តើវិធីមួយណាប្រសើរជាង - ឡាស៊ែរ ឬ កំដៅអគ្គិសនី?

ឡាស៊ែរ ឬ កំដៅអគ្គិសនី គឺជាសម្ភារៈដែលវេជ្ជបណ្ឌិតអាចប្រើដើម្បីដុតជាលិកា។ គេអាចប្រើវិធីទាំងពីរសំរាប់ដុត endometriosis (ការយកចេញ) ឬ កាត់វាចេញ។ វិធីទាំងពីរមានគុណសម្បត្តិ និង គុណវិបត្តិ។ អ្នកឯកទេសជំងឺស្ត្រី នឹងប្រើវិធីដែលខ្លួនមានបទពិសោធន៍ច្រើនបំផុត និងមានភាពកក់ក្តៅនឹងអនុវត្ត។

## ការដុត ឬ ការកាត់

គ្រាសព្វថ្ងៃនេះ  យើងកំពុងធ្វើការស្រាវជ្រាវនៅឯ Royal Women's Hospital ដើម្បីឲ្យដឹងថា តើវិធីមួយណាទៅដែលជាវិធីព្យាបាលមានប្រសិទ្ធភាពបំផុត។ យ៉ាងណាមិញ  នៅតាមកន្លែងខ្លះ  ការកាត់វាចេញ ទំនងជាមានភាពប្រសើរជាង។

## លទ្ធភាពគ្រោះថ្នាក់

ការវះកាត់ទាំងអស់មានលទ្ធភាពគ្រោះថ្នាក់។ វិធីវះឆ្លុះមើលក្នុងសំបុកពោះ កំរធ្វើឲ្យកើតមានបញ្ហាណាស់ ប៉ុន្តែវាអាចបណ្តាលឲ្យមានបញ្ហាភាពធ្ងន់ធ្ងរ។ បញ្ហាទាំងនេះមានរួមទាំង :

- ដំបៅនៅក្នុងប្លោកនោម  ស្បូន ឬ ការមុតនៅក្នុងពោះ
- ការខូចខាតសរីរាង្គ ឬ ចេញឈាម - (មួយក្នុងចំណោមប្រាំរយ)
- ស្លាប់ - (មួយក្នុងចំណោមពីរម៉ឺន)។

លទ្ធភាពគ្រោះថ្នាក់ជាក់លាក់នៃការព្យាបាល endometriosis ដោយប្រើវិធីវះឆ្លុះមើលក្នុងសំបុកពោះ មានរួមទាំង:

- ការខូចខាតពោះវៀន
- ការខូចខាតប្លោកនោម ឬ ស្បូន

ស្ថានភាពមិនល្អទាំងនេះ អាចតម្រូវឲ្យមានការព្យាបាលជាបន្ទាន់។ ស្ថានភាពទាំងនេអាចធ្ងន់ធ្ងរ ហើយអាចតម្រូវឲ្យមានការវះកាត់ធំដុំបន្ថែម នៅពេលក្រោយមកទៀត។

លទ្ធភាពគ្រោះថ្នាក់ផ្សេងទៀត មានរួមទាំង :

- លទ្ធភាពដែលរោគសញ្ញាគ្មានភាពប្រសើរជាងមុនទេ
- ការកើតមានស្លាកស្នាម (ការស្អិតជាប់)។

នៅក្នុងករណីខ្លះ  គេប្រហែលជាគ្មានលទ្ធភាពឯកយកចេញ endometriosis ទាំងអស់ទេ ឬមួយ endometriosis អាចវិលមកវិញ នៅពេលក្រោយមកទៀត។

មុនពេលវះកាត់  វេជ្ជបណ្ឌិតអ្នកត្រូវពិភាក្សាអំពីលទ្ធភាពគ្រោះថ្នាក់ជាមួយអ្នក  ដើម្បីឲ្យអ្នកយល់នូវអ្វីទៅដែលជាលទ្ធភាពគ្រោះថ្នាក់ នៅពេលអ្នកផ្តល់ការអនុញ្ញាត។

*សូមកុំភ័យខ្លាចក្នុងការសាកសួរសំណួរឡើយ*

## ការត្រៀមលក្ខណៈនៃពោះវៀន

ការត្រៀមលក្ខណៈនៃពោះវៀន អាចផ្តល់ឲ្យគ្រូពេទ្យវះកាត់នូវការមើលឃើញកាន់តែប្រសើរឡើងនូវម្តុំសាច់ដុំឆ្អឹងត្រគាករបស់អ្នក ក្នុងអម្លុងពេលវះកាត់ (ហើយធ្វើឲ្យការវះកាត់រឹតតែងាយស្រួល)។ ស្ត្រីម្នាក់ក្នុងចំណោមបីពាន់នាក់នឹងកើតមានរបួសពោះវៀនដោយចៃដន្យ ក្នុងអម្លុងការវះកាត់នេះ។ ការត្រៀមលក្ខណៈពោះវៀនជាមុន នឹងធ្វើឲ្យការជាសះរបស់ពោះវៀន រឹតតែងាយស្រួល និង រឹតតែមានសុវត្ថិភាព។

## តើប្រតិបត្តិការវះកាត់នេះ អាចព្យាបាល endometriosis ទាំងអស់ឬទេ?

មិនអាចទេ! ជាពិសេសជាមួយនឹង endometriosis ធ្ងន់ធ្ងរ ឬ នៅពេលដែលវាស្ថិតនៅនឹងកន្លែងជាក់លាក់ (ឧទាហរណ៍: នៅក្បែរនឹងពោះវៀន ឬ ស្បូន) នោះការវះកាត់បន្ថែមអាចជាការចាំបាច់។ វិធីវះឆ្លុះមើលក្នុងសំបុកពោះ នឹងជួយឲ្យវេជ្ជបណ្ឌិតដឹងថែមទៀតអំពីស្ថានភាពរបស់អ្នក ហើយវេជ្ជបណ្ឌិតអាចគ្រោងធ្វើការវះកាត់បន្ថែមឲ្យរឹតតែមានប្រសិទ្ធភាពឡើង។

បើអ្នកពិតជាត្រូវការការវះកាត់បន្ថែម នោះវាទំនងជាការវះកាត់បើកមុខ ជាជាងវិធីវះឆ្លុះមើលក្នុងសំបុកពោះ។

## Endometriosis ដែលជាប់ទាក់ទងនឹងពោះវៀន

បើពុំមានរោគសញ្ញាពោះវៀនទេ ការព្យាបាលប្រហែលជាមិនត្រូវការទេ។ បើរោគសញ្ញាពោះវៀនមានភាពធំដុំ ផ្នែកមួយនៃពោះវៀនអាចត្រូវកាត់យកចេញ។ ជួនកាលទៅ គ្រូពេទ្យអាចធ្វើការវះកាត់នេះដោយប្រើវិធីវះឆ្លុះមើលក្នុងសំបុកពោះ ប៉ុន្តែភាគច្រើន គេត្រូវធ្វើតាមរយៈការវះកាត់បើកមុខ។ បើត្រូវធ្វើយ៉ាងនេះមែន គ្រូពេទ្យវះកាត់ឯកទេសពោះវៀននឹងត្រូវចូលរួម។

## ភាពប្រសើរឡើងនៃរោគសញ្ញា

នៅក្នុងករណីភាគច្រើន រោគសញ្ញាមានភាពប្រសើរឡើង ជាធម្មតាគឺរយៈពេលយ៉ាងយូរ។ នៅក្នុងករណីខ្លះ នៅពេលដែលរោគសញ្ញាមិនមែនដោយសារ endometriosis ទេ ឬ នៅពេលដែលគ្មានលទ្ធភាពយកវាចេញទាំងស្រុង នោះរោគសញ្ញាអាចមានភាពប្រសើរខ្លះ។ យ៉ាងណាមិញ ជួនកាលទៅ រោគសញ្ញានឹងគ្មានភាពប្រសើរឡើងសោះឡើយ។

## ភាពប្រសើរឡើងនៃការអាចមានកូន

ចំពោះស្ត្រីដែលមាន endometriosis មិនសូវខ្លាំងក្លា ហើយដែលបាននិងកំពុងខិតខំមានផ្ទៃពោះ ភាពអាចមានផ្ទៃពោះរបស់ស្ត្រីទាំងនោះទំនងជាមានភាពប្រសើរឡើង ក្នុងអម្លុងពេលក្រោយការវះកាត់។ ចំពោះស្ត្រីដែលមិនបានខិតខំមានផ្ទៃពោះនៅមុនពេលវះកាត់វិញ នោះគេមិនដឹងនូវផលប៉ះពាល់នៃការវះកាត់ទៅលើភាពអាចមានផ្ទៃពោះរបស់ស្ត្រីទាំងនោះទេ។

## តើប្រតិបត្តិការវះកាត់នេះ ព្យាបាលខ្ញុំកុំឲ្យមាន endometriosis វៀងរហូតឬ?

ការសិក្សាបានបង្ហាញថា ក្នុងពេលប្រាំឆ្នាំ ស្ត្រីដល់ទៅ 70% នឹងគ្មានភស្តុតាងនៃការវិលមកវិញនៃ endometriosis ឡើយ។

## ទីកន្លែងទទួលពត៌មានបន្ថែម

**Women’s Health Information Centre (RWH)**
(03) 8345 3045
1800 442 007 (ទូរស័ព្ទដោយឥតគិតថ្លៃ) អ៊ីមែល : whic@thewomens.org.au
http://www.thewomens.org.au

**Endometriosis Association of Victoria**
567 Waterdale Road
Heidelberg West
Victoria 3081
Australia
(03) 9457 2933
http://www.endometriosis.org.au/

**Gynaecology Clinic (គ្លីនិកជំងឺស្ត្រី) នៅ Royal Women’s Hospital**

គ្លីនិកនេះ មានទីតាំងនៅក្នុងអគារ outpatients (អ្នកជំងឺនៅក្រៅមន្ទីរពេទ្យ) នៅនឹងជាន់ក្រោមនៃ Royal Women’s Hospital
ទូរស័ព្ទ (03) 8345 2000

## បណ្ណ័ពត៌មានឯទៀតរបស់ RWH ដែលអាចមានប្រយោជន៍សំរាប់អ្នក

RWH មានបណ្ណ័ពត៌មានផ្សេងៗជាភាសាច្រើន នៅតាមអ៊ីនធើរណិត។ បើអ្នកចង់បានពត៌មានបន្ថែម អ្នកអាចបើកមើលវិបសៃផ្សព្វផ្សាយសុខភាពរបស់យើង។ អាសយដ្ឋានគឺ
http://www.thewomens.org.au

អ្នកក៏អាចសុំឲ្យអ្នកថែទាំអ្នកនៅ Royal Women’s Hospital ផ្តល់បណ្ណ័ពត៌មានផងដែរ។ សុំយក :

- *Endometriosis (ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង) – ពត៌មានសំរាប់ស្ត្រី*
- *ការព្យាបាល endometriosis (ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង)*